ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១៧១
ចុះថ្ងៃទី ២៣-០២-២០១២
សាលដីកា
លេខ ៖ ៧២ "ក្រ.III.ស"
ចុះថ្ងៃទី ២១-០៨-២០១៣

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ១៧១ ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០១២ ដែលមាន:

- ជនជាប់ចោទឈ្មោះ [redacted] ជាន់ពីដែល ហៅ ជ្រូក ភេទប្រុស អាយុ ៤១ឆ្នាំ ជាតិខ្មែរ មុខរបរគ្មាន កើតនៅសង្កាត់លេខ ៥ ក្រុងភ្នំពេញ ទីលំនៅសព្វថ្ងៃផ្ទះ [redacted] សង្កាត់អូរឬស្សី ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ១នាក់ ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី ១០ ខែតុលា ឆ្នាំ២០១១។

មានលោក [redacted] វិសាល ជាមេធាវីការពារ។

**ជាប់ចោទពីបទ:** ជួញដូរគ្រឿងញៀន ប្រព្រឹត្តនៅចំណុចខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៣ ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## ឯដំណើររឿងមានដូចតទៅ

កាលពីថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០១១ វេលាម៉ោង ២១ និង៥០នាទី យប់ នៅចំណុចខណ្ឌ៧មករា រាជធានីភ្នំពេញ កម្លាំងប៉ុស្តិ៍ និងប្រជាការពារសង្កាត់មនោរម្យបានឃាត់ខ្លួនអ្នកចែកចាយគ្រឿងញៀនឈ្មោះ [redacted] ធារ៉ា នៅចំណុចច្រកជណ្តើរលេខ ៣៨E២ ផ្លូវ ១០៧ ភូមិ ៨ សង្កាត់មនោរម្យ មកស្នាក់ការប៉ុស្តិ៍។ ក្រោយពីការសាកសួរឈ្មោះ [redacted] ធារ៉ា បានសារភាពថា គ្រឿងញៀនដែលនៅនឹងខ្លួន ១

នេះ គឺខ្លួនបានទិញពីឈ្មោះ [redacted] ផាន់ពីដែល ហៅ ជ្រូក ហើយឈ្មោះ [redacted] ផាន់ពីដែល បានឱ្យឈ្មោះ [redacted] ភារិន ជាអ្នកយកគ្រឿងញៀនមកឱ្យខ្លួន។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១០ កប៤ ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ:

១- ផ្ដន្ទាទោស:

ក- ឈ្មោះ [redacted] ភារិន ហៅ រិន ភេទប្រុស អាយុ ២៥ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ២ (ពីរ) ឆ្នាំ។

ខ- ឈ្មោះ [redacted] ផាន់ពីដែល ហៅ ជ្រូក ភេទប្រុស អាយុ ៤១ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៣ (បី) ឆ្នាំ។

ពីបទ ជួញដូរគ្រឿងញៀន ប្រព្រឹត្តនៅចំណុចខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០១១ តាមមាត្រា ៣៣ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្ម ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

គ- ឈ្មោះ [redacted] ធារ៉ា ភេទប្រុស អាយុ ២៥ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១ (មួយ) ឆ្នាំ។

ពីបទ ចែកចាយគ្រឿងញៀន ប្រព្រឹត្តនៅចំណុចខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០១១ តាមមាត្រា ៣៦ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្ម ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

២- វត្ថុចាប់យកមាន:

ក- ស្រោមសំបុត្រពណ៌សចំនួន ០១ បិទជិត ដែលមានហត្ថលេខាសមត្ថកិច្ច និងស្នាមមេដៃជនសង្ស័យឈ្មោះ [redacted] ភារិន នៅលើស្រោមសំបុត្រសរសេរថា ក្រាមពណ៌សថ្លាប្រភេទ មេតំហ្វេតាមីនទម្ងន់ 0,១២ក្រាម (សូន្យក្បៀសដប់ពីរក្រាម) និងសំបកថង់ផ្លាស្ទិកសម្រាប់ច្រកគ្រឿងញៀនចំនួន ០២។

ខ- ដបទឹកសុទ្ធចំនួន ០១ ទុយោចំនួន ០២ និងដែកកេះពណ៌លឿងចំនួន ០១ ត្រូវរឹបអូសបំផ្លាញចោល។

គ- ទូរស័ព្ទដៃមួយគ្រឿងម៉ាក HUAWIE MODEL F ២១០១ ពណ៌ខ្មៅលាយស មានស៊ីម។

ឃ- ទូរស័ព្ទដៃមួយគ្រឿងម៉ាក I Phone ផលិតនៅប្រទេសចិនពណ៌ខ្មៅបិទស្កុតពណ៌សូកូឡា មានស៊ីម។ ដូចមាននៅក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ ៥០៣ វ.ត ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០១១ ត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១២។ បើកសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

- បានឃើញ សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ផាន់ពីដែល ជាជនជាប់ចោទ ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១០ កប៤ ចុះថ្ងៃទី ៣១

ខែមករា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។
- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ជនជាប់ចោទឈ្មោះ [redacted] ផាន់ពីដែល ឆ្លើយថាៈ ខ្លួនប្ដឹងឧទ្ធរណ៍មកនេះសុំលោកប្រធានមេត្តាបន្ធូរបន្ថយទោសខ្លួនផង ខ្លួនជាប់ពន្ធនាគារ ១ឆ្នាំ ១០ខែ ហើយ។ ខ្លួនទទួលស្គាល់ថា ខ្លួនបានទទួលយកថ្នាំញៀនទៅលក់ឲ្យគេមែន តែមានលក្ខណៈតិចតួចទេ ខ្លួនដឹងកំហុសហើយ។

### សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ផាន់ពីដែល ជាជនជាប់ចោទ បានធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់។

សាលក្រមព្រហ្មទណ្ឌលេខ ១០ កប៤ ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ មានសំអាងហេតុ សំអាងច្បាប់សមស្របតាមគតិច្បាប់ ហើយគប្បីតម្កល់ទុកជាបានការដដែល។

### សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ក្រោយការសួរដេញដោលកូនក្ដីខ្លួនបានសារភាពថា ពិតជាបានជួញដូរគ្រឿងញៀនពិតប្រាកដមែន កូនក្ដីខ្លួនប្ដឹងឧទ្ធរណ៍ដើម្បីសុំឲ្យសាលាឧទ្ធរណ៍បន្ធូរបន្ថយទោសឲ្យគាត់ផង។ រឿងនេះព្យសនកម្មមានលក្ខណៈតិចតួច សុំលោកប្រធានមេត្តាបន្ធូរបន្ថយទោសដល់កូនក្ដីខ្លួន, តាមមាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌ។

- ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថាៈ

១- បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ផាន់ពីដែល ជាជនជាប់ចោទ ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- នៅសវនាការនេះជនជាប់ចោទបានឆ្លើយសារភាពថា រយៈកន្លងទៅខ្លួនពិតជាបានរកស៊ីចែកចាយគ្រឿងញៀនមែន ប៉ុន្តែតូចតាចមានចំនួនតិចតួច ដើម្បីដោះស្រាយជីវភាពខ្វះខាត។

៣- តាមចម្លើយសាក្សីឈ្មោះ [redacted] ធារ៉ា ថា នៅថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០១១ ជនជាប់ចោទបានឲ្យឈ្មោះ [redacted] ភារិន យកថ្នាំញៀនមួយកញ្ចប់តូចមកឲ្យខ្លួនមែន។

តាមន័យនេះ ឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើជួញដូរគ្រឿងញៀនខុសច្បាប់មែន ប៉ុន្តែពុំមែនជាអាជីវកម្ម ឬជាមុខរបរធំដុំទេ គ្រាន់តែបានកម្រៃតិចតួចសម្រាប់ដោះស្រាយការខ្វះខាតផ្ទាល់ប៉ុណ្ណោះ។

៤- មានភស្តុតាងបញ្ជាក់ពិរុទ្ធភាពលើជនជាប់ចោទ ពីបទ ជួញដូរគ្រឿងញៀន ប្រព្រឹត្តនៅខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០១១ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ដោយសកម្មភាពមានភាពតូច គ្រឿងញៀនមានចំនួនតិចតួច គួរកែប្រែបន្ថយកកម្រិតទណ្ឌកម្មដាក់ពន្ធនាគារឲ្យបានសមស្រប។

៥- សាលក្រមព្រហ្មទណ្ឌលេខ ១០ កប៤ ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចមានលក្ខណៈត្រឹមត្រូវ គួរតម្កល់ទុកជាបានការ លើកលែងតែកម្រិតទណ្ឌកម្មនៅចំណុចទី ១ លើជនជាប់ចោទឈ្មោះ [redacted] ផាន់ពីដែល គួរកែប្រែដូចយល់ឃើញខាងលើ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ផាន់ពីដែល ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១០ កប៤ ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែកម្រិតទណ្ឌកម្មនៅចំណុចទី ១ លើជនជាប់ចោទឈ្មោះ [redacted] ផាន់ពីដែល ត្រូវកែប្រែទៅជា ២ឆ្នាំ ៦ខែ (ពីរឆ្នាំប្រាំមួយខែ)វិញ, ក្រៅពីនេះទុកនៅដដែល។

៣- បង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០១៣ ប្រកាសជាសាធារណៈនៅថ្ងៃទី ២១ ខែសីហា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ បើកផ្លូវសាទុក្ខ ០១ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកានេះទៅ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។៚**

**ក្រឡាបញ្ជី** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខា: [redacted] ហត្ថលេខា: [redacted] **ប្លង់ សំណាង** ហត្ថលេខា: [redacted]

បានឃើញ

**ប្រធានសាលាឧទ្ធរណ៍**

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី ០៤ ខែ 6 ឆ្នាំ ២០១៤

**ក្រឡាបញ្ជី**